# អត្ថបទ
# ស្តីពី
# លក្ខខណ្ឌសុពលភាព
# និង
# ការរំលាយកិច្ចសន្យា

រៀបរៀងដោយ៖លោក ជួប មិតរបេរម្ឃន្ធិ

បណ្ណាល័យច្បាប់-Law Library
lawlibrarysite.wordpress.com

# ចំណោតស្រាយ

**សំណួរទី១៖** ចូរពន្យល់អំពីលក្ខខណ្ឌសុពលភាព និងការរំលាយកិច្ចសន្យា តាមក្រមរដ្ឋប្បវេណី។

កិច្ចសន្យា គឺជាកិរិយាដែលបុគ្គលពីរនាក់ ឬច្រើននាក់ មានឆន្ទៈត្រូវគ្នាព្រមបង្កើត កែប្រែ ឬរំលត់នូវកាតព្វកិច្ច[1]។ កិច្ចសន្យា ជាប្រភពមួយនៃការបង្កើតឱ្យមានកាតព្វកិច្ច ដែលជាចំណងគតិយុត្តិចងបុគ្គលពីរនាក់ ដោយឱ្យបុគ្គលម្នាក់ដែលបានកំណត់ មានករណីយកិច្ចមួយចំនួន ចំពោះបុគ្គលដែលបានកំណត់ម្នាក់ទៀត។

តើមានលក្ខខណ្ឌអ្វីខ្លះដើម្បីឱ្យកិច្ចសន្យាមួយមានសុពលភាព? ហើយត្រូវមានលក្ខខណ្ឌយ៉ាងដូចម្ដេចដែរ ដែលនាំឱ្យគេអាចរំលាយកិច្ចសន្យាបាន?

## ១. លក្ខខណ្ឌសុពលភាពនៃកិច្ចសន្យា

កិច្ចសន្យា មានអនុភាពនៅពេលដែលសំណើ និងស្វីការត្រូវគ្នា[2]។ ប៉ុន្តែនៅក្នុងករណីដែលការបង្ហាញឆន្ទៈមានវិការៈ ឬខ្លឹមសារនៃសកម្មភាព[3]នេះផ្ទុយនឹងច្បាប់ ឬភាពត្រឹមត្រូវនៅក្នុងសង្គម នោះអនុភាពនឹងត្រូវបានបដិសេធដោយក្រមរដ្ឋប្បវេណី។ ដូចនេះ ដើម្បីឱ្យកិច្ចសន្យាមួយមានសុពលភាព កិច្ចសន្យានោះត្រូវបំពេញឱ្យបាននូវលក្ខខណ្ឌចាំបាច់ គឺសំណើ និងស្វីការត្រូវគ្នា និងលក្ខខណ្ឌគ្រប់គ្រាន់ គឺមាន (១) លក្ខខណ្ឌទូទៅទាក់ទងនឹងភាគី ដែលរួមមាន សមត្ថភាពទទួលសិទ្ធិ សមត្ថភាពខាងឆន្ទៈ សមត្ថភាពក្នុងការធ្វើសកម្មភាព និងគ្មានវិការៈក្នុងការបង្ហាញឆន្ទៈ និង(២) លក្ខខណ្ឌទូទៅទាក់ទងនឹងខ្លឹមសារនៃកិច្ចសន្យា ដែលរួមមាន ភាពច្បាស់លាស់ ភាពស្របច្បាប់ ភាពសមស្របតាមស្ថានភាពសង្គម និងភាពគ្មានការបង្ហាញឆន្ទៈមិនពិត។

### ១.១ លក្ខខណ្ឌទូទៅទាក់ទងនឹងភាគី

លក្ខខណ្ឌទូទៅទាក់ទងនឹងភាគីដើម្បីឱ្យកិច្ចសន្យាមានសុពលភាព គឺ ភាគីត្រូវមានសមត្ថភាពទទួលសិទ្ធិ ត្រូវមានសមត្ថភាពខាងឆន្ទៈ ត្រូវមានសមត្ថភាពក្នុងការធ្វើសកម្មភាព និងគ្មានវិការៈក្នុងការបង្ហាញឆន្ទៈ។ ការកម្រិតលក្ខខណ្ឌបែបនេះ ក្នុងគោលបំណងដើម្បីការពារកុំឱ្យមានការខូចខាតដល់កិច្ចការជំនួញរបស់ជនទាំងឡាយដែលខ្វះសមត្ថភាពដូចបានកំណត់ខាងលើ។

#### ក. ភាគីត្រូវមានសមត្ថភាពទទួលសិទ្ធិ

សំដៅទៅលើស្ថានភាពជាក់លាក់របស់រូបវ័ន្តបុគ្គលម្នាក់ៗដែលជាភាគី ក្នុងការទទួលបាននូវសិទ្ធិ ដូចជាសិទ្ធិក្នុងការបង្កើតកិច្ចសន្យា សិទ្ធិទទួលបានមរតក សិទ្ធិទាមទារសំណងខូចខាត ជាដើម។ ជាគោលការណ៍ រូបវន្តបុគ្គលគ្រប់រូប មានសមត្ថភាពទទួលបាននូវសិទ្ធិបុគ្គល ដូចៗគ្នា មិនថា ជាជនជាតិខ្មែរ ឬបរទេសឡើយ។ ប៉ុន្តែ ជនជាតិបរទេសមិនអាចទទួលបាន ឬកាន់កាប់នូវសិទ្ធិមួយចំនួន ដែលត្រូវបានកំណត់ឡើយ ក្នុងករណីមានបញ្ញត្តិផ្សេងនៅក្នុងច្បាប់ ឬសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ[4]។ ជាក់ស្ដែង នៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៤៤ កថាខណ្ឌទី១ បានចែងថា "មានតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ញាតិខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី"។

#### ខ. ភាគីត្រូវមានសមត្ថភាពខាងឆន្ទៈ

[1] ក្រមរដ្ឋប្បវេណី មាត្រា៣១១។

[2] ក្រមរដ្ឋប្បវេណី មាត្រា៣៣៦ កថាខណ្ឌទី១។

[3] ពាក្យ "សកម្មភាព" នៅទីនេះ សំដៅទៅលើកិច្ចសន្យា ឬសកម្មភាពឯកតោភាគី។

[4] ក្រមរដ្ឋប្បវេណី មាត្រា៧។

សំដៅទៅលើភាគីដែលមានសមត្ថភាពអាចយល់ដឹង និងវិនិច្ឆ័យបានអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន បើមិនដូច្នោះទេសកម្មភាពនោះ អាចនឹងត្រូវលុបចោលបាន[5]។

**គ. ភាគីត្រូវមានសមត្ថភាពក្នុងការធ្វើសកម្មភាព**

សំដៅទៅលើជនក្រៅពីជនដែលត្រូវបានកម្រិតសមត្ថភាពធ្វើសកម្មភាព ដូចដែលបានកំណត់នៅក្នុងមាត្រា១៦នៃក្រមរដ្ឋប្បវេណី។ ជនដែលត្រូវបានកម្រិតសមត្ថភាព មានបីប្រភេទ គឺអនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ និងជននៅក្រោមហិតូបត្ថម្ភ។ កិច្ចសន្យាដែលបង្កើតឡើងដោយជនក្រៅពីជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព គឺមានសុពលភាពពេញលេញ ប្រសិនបើពុំមានមូលហេតុផ្សេងទៀតដែលនាំឱ្យមោឃៈ ឬមូលហេតុដែលអាចលុបចោលកិច្ចសន្យាបាន។

**ឃ. ភាគីគ្មានវិការៈក្នុងការបង្ហាញឆន្ទៈ[6]**

ភាពគ្មានវិការៈក្នុងការបង្ហាញឆន្ទៈ សំដៅទៅលើការបង្ហាញឆន្ទៈដែលមានសុពលភាព ដែលជាលក្ខខណ្ឌដើម្បីឱ្យកិច្ចសន្យាមានអនុភាពចងភាគីទាំងពីរ។ ក្នុងករណីដែលការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយការភាន់ច្រឡំ ដោយការឆបោក ឬការគម្រាមកំហែង ឬការបង្ហាញការមិនពិតរបស់ភាគីម្ខាងទៀត និងដោយអំពើឆ្លៀតឱកាសដោយមានគោលបំណងកេងយកចំណេញហួសហេតុ នោះគេហៅថា ការបង្ហាញឆន្ទៈដែលមានវិការៈ។ ក្នុងករណីបែបនេះ កិច្ចសន្យាអាចត្រូវបានលុបចោល ដោយសារមានវិការៈក្នុងការបង្ហាញឆន្ទៈ។

## ១.២ លក្ខខណ្ឌទូទៅទាក់ទងនឹងខ្លឹមសារនៃកិច្ចសន្យា

ខ្លឹមសារនៃកិច្ចសន្យា គឺជាលក្ខខណ្ឌមួយទៀត ដើម្បីធ្វើឱ្យកិច្ចសន្យាមួយមានសុពលភាពពេញលេញ។ លក្ខខណ្ឌទូទៅទាក់ទងនឹងខ្លឹមសារនៃកិច្ចសន្យា មាន៤ ដូចខាងក្រោមៈ

**ក. ភាពច្បាស់លាស់**

ប្រសិនបើកិច្ចសន្យាមានភាពមិនច្បាស់លាស់ វានឹងនាំឱ្យមោឃៈ ព្រោះខ្លឹមសារនៃកាតព្វកិច្ចក្នុងកិច្ចសន្យាមិនអាចយកទៅអនុវត្តបានតាមរយៈតុលាការ។ ឧទាហរណ៍ លោក A បានសន្យាថា បើ B អាយុ ១៨ឆ្នាំ លោក A នឹងឱ្យអ្វីៗដែលល្អដល់ B ។ ចំពោះខ្លឹមសារនៃការសន្យាបែបនេះ តុលាការមិនអាចចេញសាលក្រម ឬមិនអាចអនុវត្តកាតព្វកិច្ចដោយបង្ខំបានទេ ដោយហេតុថា ខ្លឹមសារនៃកិច្ចសន្យាមានភាពមិនច្បាស់លាស់។ ក៏ប៉ុន្តែ វាមិនមានភាពចាំបាច់ទេក្នុងការសម្រេចថា រាល់ខ្លឹមសារទាំងអស់នៅក្នុងកិច្ចសន្យា ត្រូវតែមានភាពច្បាស់លាស់។ វាគឺមានលក្ខណៈគ្រប់គ្រាន់ដែលបង្ហាញពីភាពច្បាស់លាស់ ប្រសិនបើផ្នែកសំខាន់នៃកិច្ចសន្យាអាចត្រូវបានបង្ហាញឱ្យឃើញច្បាស់តាមរយៈការបកស្រាយ។ ដូចនេះ ភាពច្បាស់លាស់នៅទីនេះ គឺសំដៅត្រឹមតែ ***ផ្នែកសំខាន់នៃកិច្ចសន្យា*** តែប៉ុណ្ណោះ។

**ខ. ភាពស្របច្បាប់**

ប្រសិនបើខ្លឹមសារនៃកិច្ចសន្យា ផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំណាមួយ នោះវាត្រូវបានចាត់ទុកជាមោឃៈ[7]។ បញ្ញត្តិដែលអនុវត្តដោយបង្ខំ គឺសំដៅទៅលើបញ្ញត្តិដែលបដិសេធរាល់អានុភាពនៃសកម្មភាពគតិយុត្ត ដែលបានធ្វើឡើងផ្ទុយនឹងបញ្ញត្តិនេះ។ ឧទាហរណ៍ នៅក្នុងករណីដែលគូភាគីបានព្រមព្រៀងគ្នាថា "ភាគីម្ខាងមិនអាចលុបចោលកិច្ចសន្យាបានទេ ទោះបីជាគាត់បានបង្ហាញឆន្ទៈដោយសារការគំរាមកំហែងក៏ដោយ" ការព្រមព្រៀងបែបនេះ ត្រូវបានចាត់ទុកជាមោឃៈ ព្រោះវាផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ។

---

[5] ក្រមរដ្ឋប្បវេណី មាត្រា១៤។

[6] សូមមើលផ្នែកទី២ "វិការៈក្នុងការបង្ហាញឆន្ទៈ និងសុពលភាពនៃកិច្ចសន្យា" មាត្រា៣៤៥ ដល់មាត្រា៣៥៥ នៃក្រមរដ្ឋប្បវេណី។

[7] ក្រមរដ្ឋប្បវេណី មាត្រា៣៥៤ កថាខណ្ឌទី១ ចំណុច ក ។

**គ. ភាពសមស្របតាមស្ថានភាពសង្គម**

លក្ខខណ្ឌនេះ សំដៅទៅលើភាពមិនផ្ទុយនឹងសណ្ដាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អរបស់សង្គម[8]។ មានន័យថា ទោះបីជាគូភាគីបង្ហាញឆន្ទៈដោយគ្មានវិការៈក៏ដោយ ក៏កិច្ចសន្យាត្រូវបានចាត់ទុកជាមោឃៈដែរ ប្រសិនបើខ្លឹមសារនៃកិច្ចសន្យាផ្ទុយពីស្ថានភាពសង្គម និងទំនៀមទម្លាប់ល្អ។

**ឃ. គ្មានការបង្ហាញឆន្ទៈមិនពិត**

លក្ខខណ្ឌនេះ សំដៅថា កិច្ចសន្យាអាចមានសុពលភាពបានលុះត្រាតែគ្មានការបង្ហាញឆន្ទៈមិនពិត។ មានន័យថា បើកិច្ចសន្យាធ្វើឡើងដោយមានការឃុបឃិតជាមួយភាគីម្ខាងទៀត ត្រូវចាត់ទុកជាមោឃៈ[9]។ ឧទាហរណ៍ លោក **ក** លក់ដីទៅលោក **ខ** ដោយឃុបឃិតគ្នា នៅក្នុងគោលបំណងបញ្ចៀសនូវការរឹបអូសពីម្ចាស់បំណុល។ បន្ទាប់មកលោក **ក** បានផ្ទេរការចុះបញ្ជីនៃដីទៅឱ្យលោក **ខ**។ នេះ គឺជាការបង្ហាញឆន្ទៈមិនពិត ដូចនេះ កិច្ចសន្យារវាងលោក **ក** និងលោក **ខ** ត្រូវបានចាត់ទុកជាមោឃៈ។

## ២. លក្ខខណ្ឌរំលាយកិច្ចសន្យា

ការរំលាយកិច្ចសន្យា សំដៅទៅលើសកម្មភាពឯកតោភាគី ដែលធ្វើឱ្យភាគីទាំងសងខាងរួចផុតពីករណីយកិច្ចរបស់ខ្លួននៅក្នុងកិច្ចសន្យា លើកលែងតែករណីយកិច្ចសងការខូចខាត ។ ការរំលាយកិច្ចសន្យា ធ្វើឱ្យមានអនុភាពជាឯកតោភាគី ហើយមិនចាំបាច់មានការព្រមព្រៀងពីភាគីម្ខាងទៀតទេ ព្រោះវាគឺជាសកម្មភាពឯកតោភាគី។

តាមមាត្រា៤០៧ នៃក្រមរដ្ឋប្បវេណី បានចែងថា "ភាគីម្ខាងនៃកិច្ចសន្យាអញ្ញមញ្ញអាចរំលាយកិច្ចសន្យាបានភ្លាមៗ ក្នុងករណីភាគីម្ខាងទៀតបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ"។ ដូចនេះ មានន័យថា លក្ខខណ្ឌនៃការរំលាយកិច្ចសន្យា មានចំនួន២ដូចខាងក្រោម៖

**ក. កិច្ចសន្យាអញ្ញមញ្ញ៖** មានន័យថា មានតែជាកិច្ចសន្យាដែលភាគីមានបន្ទុកបំពេញកាតព្វកិច្ចទៅវិញទៅមក (ដូចជា កិច្ចសន្យាម៉ៅការ ភតិសន្យា កិច្ចសន្យាលក់ទិញ) ទើបជាកម្មវត្ថុនៃការរំលាយកិច្ចសន្យារបស់ភាគីម្ខាង ដោយសារភាគីម្ខាងទៀតមិនអនុវត្តកាតព្វកិច្ច។ ចំណែកឯ កិច្ចសន្យាឯកតោភាគី ដូចជាកិច្ចសន្យាប្រទានកម្ម គឺមិនចាំបាច់ទទួលស្គាល់ការរំលាយទេ។

**ខ. ការបំពានកិច្ចសន្យាធ្ងន់ធ្ងរ ដោយភាគីម្ខាង៖** នេះជាលក្ខខណ្ឌមួយទៀតដើម្បីអាចរំលាយកិច្ចសន្យាបាន។ តើអ្វីទៅជា "ការបំពានកិច្ចសន្យាធ្ងន់ធ្ងរ"? តាមមាត្រា៤០៨ បានកំណត់ន័យថា ករណីណាមួយក្នុងចំណោម៤ចំណុច ដូចខាងក្រោម គឺជាការបំពានកិច្ចសន្យាធ្ងន់ធ្ងរ។

*(១) <u>ការរំលាយកិច្ចសន្យាដោយមូលហេតុការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច៖</u>* ប្រសិនបើភាគីម្ខាងបានដាស់តឿនភាគីម្ខាងទៀត ដែលមិនបានអនុវត្តកាតព្វកិច្ចតាមពេលកំណត់ ដោយកំណត់អំឡុងពេលសមស្របដើម្បីឱ្យអនុវត្តកាតព្វកិច្ច ហើយកាតព្វកិច្ចមិនត្រូវបានអនុវត្តក្នុងអំឡុងពេលនោះ ភាគីអាចរំលាយកិច្ចសន្យាបានភ្លាម[10]។ ឧទាហរណ៍ លោករ៉ា បានចុះកិច្ចសន្យាលក់ឡានជាមួយលោកផាវ ហើយលោករ៉ា បានប្រគល់ឡានទៅឱ្យលោកផាវ។ ក៏ប៉ុន្តែលោកផាវ មិនទាន់បានបង់ប្រាក់ថ្លៃទិញទៅឱ្យលោករ៉ា នាកាលបរិច្ឆេទនោះនៅឡើយទេ។ នៅក្នុងករណីនេះ ប្រសិនបើលោករ៉ា ដាស់តឿនលោកផាវឱ្យបង់ប្រាក់ថ្លៃទិញដោយកំណត់អំឡុងពេលសមរម្យសម្រាប់អនុវត្តកាតព្វកិច្ច ហើយលោកផាវ នៅតែមិនបានបង់ប្រាក់ថ្លៃទិញ នៅក្នុងអំឡុងពេលនោះទៀត លោករ៉ា អាចរំលាយកិច្ចសន្យាបាន។ ដូចនេះ ករណីនេះមានលក្ខខណ្ឌ ចំនួន៣ ដូចខាងក្រោម៖

---

[8] ក្រមរដ្ឋប្បវេណី មាត្រា៣៥៤ កថាខណ្ឌទី១ ចំណុច ខ ។

[9] ក្រមរដ្ឋប្បវេណី មាត្រា៣៥៣។

[10] ក្រមរដ្ឋប្បវេណី មាត្រា៤០៨ កថាខណ្ឌទី១ ចំណុច ក ។

- កូនបំណុលមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួនតាមពេលកំណត់
- ម្ចាស់បំណុលដាស់តឿនភាគីដែលមិនអនុវត្តកាតព្វកិច្ចឱ្យអនុវត្តកាពត្វកិច្ច ដោយកំណត់អំឡុងពេលសមរម្យសម្រាប់អនុវត្ត
- កូនបំណុល មិនអនុវត្តកាតព្វកិច្ចនៅក្នុងអំឡុងពេលសមរម្យ។

(២) *ការរំលាយកិច្ចសន្យាដោយសារការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច ក្នុងករណីដែលពេលវេលា គឺជាចំណុចសំខាន់៖* នៅក្នុងករណីដែលគោលបំណងនៃកិច្ចសន្យា មិនបានសម្រេចប្រសិនបើការអនុវត្តកាតព្វកិច្ចមិនត្រូវបានបំពេញនៅក្នុងពេលកំណត់នោះ វាត្រូវបានគេចាត់ទុកថាជា "ការបំពានកិច្ចសន្យាធ្ងន់ធ្ងរ" ប្រសិនបើកូនបំណុលមិនបានបំពេញកាតព្វកិច្ចនៅពេលកំណត់នោះ[11]។ ឧទាហរណ៍ លោក **ក** បញ្ជាឱ្យជាងកាត់សំលៀកបំពាក់ **ខ** កាត់សំលៀកបំពាក់អាពាហ៍ពិពាហ៍ សម្រាប់ស្លៀកក្នុងពិធីរៀបអាពាហ៍ពិពាហ៍ នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១២។ ប៉ុន្តែដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១២ មកដល់ហើយ ជាងកាត់សំលៀកបំពាក់មិនទាន់ដេររួចរាល់ទៀត។ ក្នុងករណីនេះ លោក **ក** អាចរំលាយកិច្ចសន្យាបាន ដោយសារ **ខ** បានបំពេញកិច្ចសន្យាធ្ងន់ធ្ងរ។ វាមានលក្ខណៈច្បាស់លាស់ថា គោលបំណងនៃកាតព្វកិច្ចនេះ មិនត្រូវបានសម្រេច ប្រសិនបើការអនុវត្តកាតព្វកិច្ច មិនត្រូវបានធ្វើឡើងតាមលក្ខណៈនៃខ្លឹមសារកិច្ចសន្យា។

(៣) *ការរំលាយកិច្ចសន្យាដោយមូលហេតុអលទ្ធភាពនៃការអនុវត្តកាតព្វកិច្ច៖* ប្រសិនបើភាគីមិនអាចអនុវត្តករណីយកិច្ចផ្តល់**តាវកាលិកចម្បង**[12]របស់ខ្លួនបាន ភាគីម្ខាងទៀតអាចរំលាយកិច្ចសន្យាបាន។ តាវកាលិកចម្បងត្រូវសម្រេចដោយផ្អែកលើលក្ខណៈ ឬខ្លឹមសារនៃកិច្ចសន្យា និងឆន្ទៈរបស់ភាគី។ ឧទាហរណ៍ លោករ៉ាចុះកិច្ចសន្យាលក់ទិញរថយន្តជាមួយ លោកផាវ។ លោករ៉ាជាអ្នកលក់ ហើយលោកផាវជាអ្នកទិញ។ ក្រោយពីបង្កើតកិច្ចសន្យារួច លោកផាវ បានបង់ថ្លៃលក់រថយន្តទៅឱ្យលោករ៉ា ក៏ប៉ុន្តែ ម៉ាស៊ីនរបស់រថយន្តនោះ គឺខូចដោយសារទឹកជំនន់ នៅមុនពេលប្រគល់។ ដូចនេះ លោកផាវមិនអាចប្រើរថយន្តបានទេ ព្រោះតាវកាលិកចម្បង "ម៉ាស៊ីន" បានខូចគឺក្លាយជាអលទ្ធភាពនៃការអនុវត្តកាតព្វកិច្ច។ ផ្ទុយទៅវិញ ចំពោះករណីដែលកូនបំណុលមិនបានអនុវត្តកាតព្វកិច្ចបន្ទាប់បន្សំ (ក្នុងករណីមានកាតព្វកិច្ចបន្ទាប់បន្សំ ក្រៅពីកាតព្វកិច្ចចម្បង) នោះម្ចាស់បំណុលមិនអាចរំលាយកិច្ចសន្យាបានទេ ដោយផ្អែកតែទៅលើការមិនអនុវត្តកាតព្វកិច្ចបន្ទាប់បន្សំនោះ។ ឧទាហរណ៍ ការបង់ថ្លៃកាត់ឈ្មោះ ឬផ្ទេរកម្មសិទ្ធិ។

(៤) *ការរំលាយកិច្ចសន្យាដោយមូលហេតុបាត់បង់ជំនឿចិត្តរវាងគូភាគី៖* បើការបំពានកិច្ចសន្យាមានភាពហួសហេតុដែលធ្វើឱ្យបាត់បង់នូវទំនុកចិត្តរវាងគូភាគី ហើយមិនអាចជឿជាក់ថា នឹងអនុវត្តកាតព្វកិច្ចនាអនាគតបាន ភាគីម្ខាងទៀតអាចរំលាយកិច្ចសន្យាបាន (មាត្រា៤០៨កថាខណ្ឌទី១ចំណុចឃ)។ ក៏ប៉ុន្តែការរំលាយកិច្ចសន្យាប្រភេទនេះ គឺពុំមានភាពច្បាស់លាស់ឡើយ។ ទំនាក់ទំនងនៃទំនុកចិត្តនៅក្នុងកិច្ចសន្យាមានភាពខុសគ្នា ចាប់ពីកិច្ចសន្យាលក់ទិញធ្វើឡើងដោយការជួបទល់មុខគ្នា ដែលទំនាក់ទំនងនៃទំនុកចិត្ត គឺមិនមានសារសំខាន់រហូតដល់កិច្ចសន្យាលក់ទិញបន្តបន្ទាប់ ឬកិច្ចសន្យាម៉ៅការដែលផ្អែកទៅលើទំនាក់ទំនងយ៉ាងខ្លាំង។

---

[11] ក្រមរដ្ឋប្បវេណី មាត្រា៤០៨ កថាខណ្ឌទី១ ចំណុច ខ ។

[12] តាវកាលិកចម្បង គឺជាសកម្មភាពដែលភាគីមិនអាចសម្រេចគោលបំណងនៃកិច្ចសន្យា ប្រសិនបើតាវកាលិកនោះមិនត្រូវបានផ្តល់ឱ្យ។

**សំណួរទី២៖** ចូរនិយាយពីចំណុចរួម និងចំណុចខុសគ្នារវាងកិច្ចសន្យាការងារមានថេរវេលាកំណត់ និងកិច្ចសន្យាការងារមានថិរវេលាមិនកំណត់ **តាមច្បាប់ស្ដីពីការងារ។**

កិច្ចសន្យាការងារ គឺជាកិច្ចសន្យាដែលបង្កើតឱ្យមានការទាក់ទងផ្នែកការងាររវាងកម្មករនយោជិត និងនយោជក។ កិច្ចសន្យានេះត្រូវនៅក្រោមវិធានអាជ្ញាគតិ ហើយអាចនឹងធ្វើទៅតាមទម្រង់ដែលភាគីទាំងសងខាងព្រមព្រៀងគ្នា[13]។ ច្បាប់ស្ដីពីការងារ ឆ្នាំ១៩៩៧ បានបែងចែកកិច្ចសន្យាការងារជាពីរប្រភេទខុសគ្នា គឺកិច្ចសន្យាការងារដែលមានកំណត់ថិរវេលា និងកិច្ចសន្យាការងារដែលមានថិរវេលាមិនកំណត់។

កិច្ចសន្យាទាំងពីរប្រភេទនេះ មានចំណុចរួម និងចំណុចខុសគ្នា (**តាមច្បាប់ការងារ**) ដូចខាងក្រោម៖

## ១. ចំណុចរួមគ្នា

### ក. ការបង្កើតកិច្ចសន្យាការងារ

ទាំងកិច្ចសន្យាដែលមានកំណត់ថិរវេលា និងកិច្ចសន្យាដែលមានថិរវេលាមិនកំណត់ ត្រូវបញ្ជាក់អំពី៖

- មុខតំណែង និងភារកិច្ចទទួលខុសត្រូវក្នុងមុខតំណែងនោះ
- ទីកន្លែងបំពេញការងារ
- ប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ (ប្រាក់ឧបត្ថម្ភ ការធានារ៉ាប់រងសុខភាព បេសកកម្ម ...)
- ច្បាប់ វិន័យ បទបញ្ជាផ្ទៃក្នុង ឬលក្ខន្តិកៈការងាររបស់ក្រុមហ៊ុន សហគ្រាស ឬគ្រឹះស្ថាន
- កិច្ចសន្យាសាកល្បង ខនៃការមិនធ្វើសកម្មភាពវិជ្ជាជីវៈប្រកួតប្រជែង និងខនៃការបញ្ចប់កិច្ចសន្យា
- ខ ឬនីតិវិធីនៃការដោះស្រាយវិវាទការងារ
- លក្ខខណ្ឌដទៃទៀតដែលទាក់ទងទៅនឹងគោលការណ៍ទូទៅនៃកិច្ចសន្យា។

### ខ. ការបញ្ចប់ ឬការរំលាយកិច្ចសន្យាការងារ

- កិច្ចសន្យាការងារទាំងពីរប្រភេទនេះ អាចត្រូវបានរំលាយដូចគ្នា តាមរយៈ**<u>ការព្រមព្រៀង</u>**របស់ភាគីទាំងសងខាង ឬដោយសារ**<u>កំហុសធ្ងន់ធ្ងរ</u>** ឬករណី**<u>ប្រធានស័ក្ដិ</u>**កើតមានឡើង[14]។ ចំពោះការរំលាយដោយការព្រមព្រៀងគ្នា ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ចំពោះមុខអធិការការងារ និងចុះហត្ថលេខាដោយភាគីទាំងពីរនៃកិច្ចសន្យា[15]។ ចំណែកឯ ការរំលាយកិច្ចសន្យាដោយសារកំហុសធ្ងន់ធ្ងរ ឬប្រធានស័ក្តិ មិនចាំបាច់គោរពកាតព្វកិច្ចនៃការឱ្យដំណឹងជាមុនទេ ហើយកំហុសបែបណាដែលត្រូវចាត់ទុកថាជាកំហុសធ្ងន់ធ្ងរ គឺមានកំណត់នៅក្នុងមាត្រា៨៣ នៃច្បាប់ស្ដីពីការងារ។
- ករណីកិច្ចសន្យាការងារត្រូវបញ្ចប់ដោយឆន្ទៈរបស់នយោជកតែម្ខាង វៀរលែងតែក្នុងករណីកំហុសធ្ងន់ធ្ងរ នោះនយោជកត្រូវតែឱ្យកម្មករនយោជិតនូវប្រាក់បណ្ដេញចេញ (មាត្រា៨៩នៃច្បាប់ការងារ)។
- ករណីការរំលាយកិច្ចសន្យាការងារតាមឆន្ទៈផ្ទាល់នៃភាគីណាមួយ ដោយគ្មានហេតុផលត្រឹមត្រូវ នោះភាគីម្ខាងទៀត អាចទាមទារសោហ៊ុយជម្ងឺចិត្ត (មាត្រា៩១ នៃច្បាប់ការងារ)។

[13] ច្បាប់ស្ដីពីការងារ មាត្រា៦៥ កថាខណ្ឌទី១ ។

[14] ច្បាប់ស្ដីពីការងារ មាត្រា៧៣ កថាខណ្ឌទី១ និងទី២ ។

[15] ច្បាប់ស្ដីពីការងារ មាត្រា៧៣ កថាខណ្ឌទី១ វាក្យខណ្ឌទី២។

## ២. ចំណុចខ្វះខាត

### ក. ការបង្កើតកិច្ចសន្យាការងារ

| កិច្ចសន្យាការងារដែលមានកំណត់ថិរវេលា | កិច្ចសន្យាការងារដែលមានថិរវេលាមិនកំណត់ |
|---|---|
| កិច្ចសន្យា **ត្រូវ**ធ្វើឡើង (មាត្រា៦៧)៖<br>• ជាលាយលក្ខណ៍អក្សរ<br>• មានកាលបរិច្ឆេទបញ្ចប់កិច្ចសន្យា<br>• មានរយៈពេលមិនលើសពី ២ឆ្នាំ<br>(ការមិនបំពេញបាននូវលក្ខខណ្ឌណាមួយក្នុងចំណោមលក្ខខណ្ឌទាំង៣ខាងលើនេះ នឹងនាំឱ្យក្លាយជាកិច្ចសន្យាការងារដែលមានថិរវេលាមិនកំណត់ដោយស្វ័យប្រវត្តិ) | កិច្ចសន្យា **អាច**ធ្វើឡើង៖<br>• ជាលាយលក្ខណ៍អក្សរ ឬដោយមាត់ទទេ<br>• ដោយមាន ឬគ្មានកាលបរិច្ឆេទនៃការបញ្ចប់កិច្ចសន្យា (បើមានកាលបរិច្ឆេទបញ្ចប់ គឺត្រូវមានរយៈពេលលើសពី២ឆ្នាំ)<br>• ដោយមិនមានកំណត់រយៈពេល (អាចតិច ឬច្រើនជាង២ឆ្នាំ) |

### ខ. ការបញ្ចប់ ឬការរំលាយកិច្ចសន្យាការងារ

| កិច្ចសន្យាការងារដែលមានកំណត់ថិរវេលា | កិច្ចសន្យាការងារដែលមានថិរវេលាមិនកំណត់ |
|---|---|
| • ផុតរលត់នៅពេលដល់កាលកំណត់[16]<br>• ការឱ្យដំណឹងមុនការផុតរលត់កិច្ចសន្យា<br>- ១០ថ្ងៃ សម្រាប់កិច្ចសន្យាលើសពី៦ខែ<br>- ១៥ថ្ងៃ សម្រាប់កិច្ចសន្យាលើសពី១ឆ្នាំ<br>• ករណីនយោជករំលាយកិច្ចសន្យាតែឯកឯងមុនកាលកំណត់ ក្រៅពីមូលហេតុនៃការព្រមព្រៀង កំហុតធ្ងន់ធ្ងរ ឬប្រធានស័ក្តិ នោះកម្មករនយោជិត មានសិទ្ធិទទួលនូវជម្ងឺចិត្ត យ៉ាងតិចស្មើនឹងប្រាក់ឈ្នួល ដែលគាត់ត្រូវបានទទួលរហូតដល់ចប់កិច្ចសន្យា។ ច្រាសមកវិញនយោជក ក៏មានសិទ្ធិទទួលជម្ងឺចិត្តយ៉ាងតិចស្មើនឹងការខូចខាតរបស់ខ្លួន ដែលបានផ្តល់ឱ្យកម្មករនយោជិត។ (មាត្រា៧៣ កថាខណ្ឌទី៣ និងទី៤)។<br>• នៅពេលបញ្ចប់កិច្ចសន្យា កម្មករនយោជិត ត្រូវទទួលបានប្រាក់បំណាច់បញ្ចប់កិច្ចសន្យា (មាត្រា៧៣ កថាខណ្ឌទី៦)។ | • អាចរំលាយដោយឆន្ទៈរបស់ភាគីតែម្ខាង (អាចជាការបណ្តេញចេញដោយនយោជក[17] ឬការលាឈប់ដោយកម្មករនយោជិតខ្លួនឯង) ដោយត្រូវគោរពកាតព្វកិច្ចនៃការឱ្យដំណឹងជាមុន ជាលាយ-លក្ខណ៍អក្សរក្នុងរយៈពេលកំណត់ដូចខាងក្រោម<br>• ការឱ្យដំណឹងអប្បបរមាមុនការរំលាយកិច្ចសន្យា<br>- ៧ថ្ងៃ សម្រាប់អ្នកធ្វើការជាប់គ្នាតិចជាង៦ខែ<br>- ១៥ថ្ងៃ សម្រាប់អ្នកធ្វើការជាប់គ្នាចាប់ពី៦ខែដល់២ឆ្នាំ<br>- ១ខែ សម្រាប់អ្នកធ្វើការជាប់គ្នាលើសពី២ឆ្នាំដល់៥ឆ្នាំ<br>- ២ខែ សម្រាប់អ្នកធ្វើការជាប់គ្នាលើសពី៥ឆ្នាំដល់១០ឆ្នាំ<br>- ៣ខែ សម្រាប់អ្នកធ្វើការជាប់គ្នាលើសពី១០ឆ្នាំ<br>• ករណីនយោជករំលាយកិច្ចសន្យាតែឯកឯងដោយគ្មានឱ្យដំណឹងមុន ឬមិនគោរពតាមរយៈពេលនៃការឱ្យដំណឹងមុន នយោជកត្រូវចេញប្រាក់ទូទាត់ជូនកម្មករនយោជិត ដូចបានកំណត់ក្នុងមាត្រា៧៧។<br>• ក្នុងរយៈពេលនៃការឱ្យដំណឹងមុន កម្មករនយោជិតមានសិទ្ធិឈប់ធ្វើការ២ថ្ងៃក្នុងមួយសប្តាហ៍ ដោយមានប្រាក់ឈ្នួលពេញ ដូចធម្មតា ដើម្បីស្វែងរកការងារមួយថ្មីទៀត (មាត្រា៧៩)។ |

[16] ច្បាប់ស្តីពីការងារ មាត្រា៧៣ កថាខណ្ឌទី១ វាក្យខណ្ឌទី១។

[17] ការបណ្តេញចេញ ចាំបាច់ត្រូវមានហេតុផលសមរម្យទាក់ទងនឹងសម្បទា ឬចរិយានៃកម្មករនយោជិត... (មាត្រា៧៤ កថាខណ្ឌ២)។

**សំណួរទី៣៖** ចូរពន្យល់ពីទម្រង់ និងបែបបទនៃការបង្កើត និងការរំលាយក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត តាម**ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម** និងបទប្បញ្ញត្តិពាក់ព័ន្ធ។

## ១. ទម្រង់ និងបែបបទនៃការបង្កើតក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

ទម្រង់ និងបែបបទនៃការបង្កើតក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត មានកំណត់នៅក្នុងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ក្នុងមាត្រា៨៦ មាត្រា៩១រហូតដល់មាត្រា៩៨ និងប្រកាសរបស់ក្រសួងពាណិជ្ជកម្ម។

### ១.១ ទម្រង់ ឬទ្រង់ទ្រាយនៃក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

ការបង្កើតក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ត្រូវមានទម្រង់ដូចខាងក្រោម៖

(១) ក្រុមហ៊ុនអាចមានសមាជិកភាគហ៊ុនពី០២រហូតដល់៣០រូប។

(២) ក្រុមហ៊ុនមិនអាចអនុញ្ញាតឱ្យលក់ភាគហ៊ុន ឬមូលប័ត្រដទៃទៀត ជាសាធារណៈបានឡើយ ប៉ុន្តែអាចអនុញ្ញាតឱ្យធ្វើអនុប្បទានទៅសមាជិកហ៊ុន សមាជិកគ្រួសារ និងអ្នកគ្រប់គ្រងបាន។ ក្នុងករណីធ្វើអនុប្បទានទៅឱ្យតតិយជន ត្រូវមានការយល់ព្រមពីសមាជិកភាគហ៊ុនដទៃទៀត តាមសម្លេងភាគច្រើន។

(៣) ក្រុមហ៊ុនអាចមានការរឹតត្បិតមួយ ឬច្រើនបានទៅលើការផ្ទេរចំណែកនៃប្រភេទភាគហ៊ុនទាំងអស់។

(៤) នាមករណ៍របស់ក្រុមហ៊ុន៖ ត្រូវមានតែមួយ និងមិនត្រូវមានពាក្យដែលត្រូវបានកំហិតមួយចំនួននោះទេ (ដូចជា ជាន់ឈ្មោះ ឬភាន់ច្រឡំនឹងនាមករណ៍របស់ក្រុមដែលបានចុះបញ្ជីរួច ឬផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ)។ វាអាចជាអក្សរខ្មែរ ឬអក្សរឡាតាំង ដោយត្រូវសរសេរនាមករណ៍ជាអក្សរឡាតាំងនៅពីក្រោមនាមករណ៍ជាអក្សរខ្មែរ ក្នុងទំហំតូចជាង។ នាមករណ៍របស់វាត្រូវដាក់ពាក្យថា "ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត" ឬសរសេរអក្សរកាត់ដាក់ខាងចុង ឬខាងក្រោម ដែលភាគច្រើនដាក់ថា "អិលធីឌី"។

(៥) មូលធនជាភាគហ៊ុន៖ ក្រុមហ៊ុនត្រូវបោះចេញយ៉ាងតិចបំផុតចំនួន ១០០០ភាគហ៊ុន ដែលមានតម្លៃចារឹកលើប័ណ្ណមិនតិចជាង ៤០០០រៀលក្នុងមួយភាគហ៊ុន។ ដូចនេះ មូលធនជាភាគហ៊ុនអប្បបរមាដើម្បីបង្កើតដំបូង គឺ៤.០០០.០០០ (បួនលាន) រៀល។

(៦) ម្ចាស់ហ៊ុន៖ ការទទួលខុសត្រូវរបស់ម្ចាស់ហ៊ុននីមួយៗ ត្រូវកម្រិតទៅតាមភាគទុនជាដើមទុនដែលគេបានវិនិយោគ។

(៧) ទីស្នាក់ការចុះបញ្ជី៖ ក្រុមហ៊ុនត្រូវតែមានទីស្នាក់ការចុះបញ្ជីស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

(៨) អភិបាលក្រុមហ៊ុន៖ ក្រុមហ៊ុនអាចមានអភិបាលម្នាក់ ឬច្រើននាក់។ អភិបាលត្រូវតែជារូបវន្តបុគ្គលមិនប្រកាន់សញ្ជាតិ លំនៅ និងនិវេសនដ្ឋាន។

(៩) ពន្ធអាករ៖ ពន្ធលើប្រាក់ចំណេញ ត្រូវបង់លើប្រាក់ចំណេញដែលទទួលបានក្នុងប្រទេសកម្ពុជា។

(១០) ការចុះបញ្ជីក្រុមហ៊ុន៖ ក្រុមហ៊ុនត្រូវបានបង្កើតឡើងដោយការដាក់ពាក្យសុំចុះបញ្ជីពាណិជ្ជកម្ម និងមានភ្ជាប់ឯកសារចាំបាច់ ព្រមទាំងបង់កម្រៃទៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម។

### ១.២ បែបបទ និងនីតិវិធីនៃការចុះបញ្ជី ដើម្បីបង្កើតក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

ក្រុមហ៊ុនទាំងអស់ត្រូវមកកាន់ការិយាល័យចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម លើកលែងតែក្នុងករណីដែលមានសាខាចុះបញ្ជីពាណិជ្ជកម្មនៅក្នុងខេត្តរបស់ខ្លួន ដើម្បីធ្វើការចុះបញ្ជីក្រុមហ៊ុន ដែលក្នុងករណីនេះក្រុមហ៊ុនត្រូវដាក់ពាក្យសុំទៅសាខានោះ។

**ជំហានទី១៖** ពិនិត្យមើលនាមករណ៍ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម៖

នាមករណ៍អាជីវកម្មដ៏មានប្រសិទ្ធភាព ត្រូវមានទំនាក់ទំនងទៅនឹងផលិតផល ឬសេវាកម្មរបស់ខ្លួន

ហើយងាយអាន ងាយប្រកប និងងាយចងចាំ។ ប្រសិនបើនាមករណ៍ដែលបានជ្រើសរើសមានច្រើន អ្នកដាក់ពាក្យសុំត្រូវរើសយកនាមករណ៍ផ្សេងទៀត។ ការស្រាវជ្រាវរកនាមករណ៍ ប្រើពេលតែ១០នាទីប៉ុណ្ណោះ។

**ជំហានទី២៖** ឯកសារតម្រូវ និងកម្រៃរដ្ឋបាលសម្រាប់ការចុះបញ្ជីក្រុមហ៊ុន មានដូចខាងក្រោម៖

| ឯកសារ | ចំនួន |
|---|---|
| ពាក្យស្នើសុំគំរូ ក | ៣ ច្បាប់ (ច្បាប់ដើម២និងចម្លង១) |
| អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនថតចម្លងរបស់ម្ចាស់ហ៊ុន និងអភិបាលទាំងអស់ដោយមានចុះហត្ថលេខា ឬស្នាមមេដៃ | ៣ សន្លឹក សម្រាប់ម្ចាស់ហ៊ុន និងអភិបាលម្នាក់ៗ |
| រូបថត (៤x៦cm) របស់ម្ចាស់ហ៊ុន និងអភិបាលនីមួយៗ | ៣ សន្លឹក |
| លិខិតធានាពីធនាគារដែលបញ្ជាក់ថា មានតម្កល់ប្រាក់យ៉ាងតិចស្មើនឹងដើមទុនអប្បបរមាចំនួន៤លានរៀល | ១ ច្បាប់ដើម |
| លក្ខន្តិកៈ (ចែងអំពីលក្ខខណ្ឌដែលមានកំណត់ក្នុងមាត្រា៩៣) | ៣ ច្បាប់ |
| **កម្រៃរដ្ឋបាលចុះបញ្ជីជាផ្លូវការ (ច្បាប់ស្តីពីសារពើពន្ធ មាត្រា៣)** | **៤២០.០០០ រៀល** |

*ករណីម្ចាស់ហ៊ុនជានីតិបុគ្គល នោះតម្រូវឱ្យមានឯកសារបន្ថែមដូចខាងក្រោម៖*

| ឯកសារ | ចំនួន |
|---|---|
| លក្ខន្តិកៈក្រុមហ៊ុនដោយមានការបញ្ជាក់ថាថតចម្លងត្រឹមត្រូវ | ១ ច្បាប់ថតចម្លង |
| វិញ្ញាបនបត្រចុះបញ្ជីក្រុមហ៊ុនដោយមានការបញ្ជាក់ថាថតត្រឹមត្រូវ | ១ ច្បាប់ថតចម្លង |
| លិខិតតែងតាំងអ្នកតំណាងនៅក្នុងក្រុមហ៊ុនថ្មីរបស់ម្ចាស់ហ៊ុនសាជីវកម្មនីមួយៗ | ១ ច្បាប់ដើម |
| រូបថតរបស់អ្នកតំណាងម្ចាស់ហ៊ុនសាជីវកម្ម | ៣ សន្លឹក |
| អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនថតចម្លង របស់អ្នកតំណាងម្ចាស់ហ៊ុន ដោយមានចុះហត្ថលេខា ឬស្នាមមេដៃ | ៣ ច្បាប់ |

**ជំហានទី៣៖** នៅពេលដែលឯកសារដូចបានរៀបរាប់ខាងលើ មានគ្រប់គ្រាន់សម្រាប់ចុះបញ្ជី អភិបាល ឬម្ចាស់ហ៊ុនណាម្នាក់របស់ក្រុមហ៊ុន ត្រូវមកបង្ហាញខ្លួននៅក្រសួងពាណិជ្ជកម្មដើម្បីចុះហត្ថលេខាលើបែបបទនៃពាក្យសុំ មុនពេលចេញវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម (ករណីពាក្យស្នើសុំធ្វើឡើងនៅសាខាចុះបញ្ជីពាណិជ្ជកម្មខេត្ត នោះការបង្ហាញខ្លួនដើម្បីចុះហត្ថលេខាក៏ត្រូវធ្វើឡើងនៅទីនោះដែរ)។

**ជំហានទី៤៖** ជាដំណាក់កាលនៃការពិនិត្យឯកសារ និងចេញវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មជូនដល់ក្រុមហ៊ុន។ ដំណើរការនេះ ត្រូវចំណាយពេលប្រហែលជា៥ថ្ងៃនៃថ្ងៃធ្វើការ។ ប្រសិនបើពាក្យបានធ្វើឡើងនៅសាខាចុះបញ្ជីពាណិជ្ជកម្មខេត្ត វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មបណ្តោះអាសន្ន នឹងត្រូវចេញជូនក្នុងអំឡុងពេល១០ថ្ងៃ។ វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មបណ្តោះអាសន្ននេះ មានសុពលភាពរយៈពេល៣០ថ្ងៃ ហើយវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មផ្លូវការ នឹងត្រូវចេញជូនក្នុងអំឡុងរយៈពេលសុពលភាពនោះ។

**ជំហានទី៥៖** នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម អាចរៀបចំឱ្យក្រុមហ៊ុនដែលទើបចុះបញ្ជីថ្មី ទទួលបានត្រាមួយធ្វើឡើងស្របតាមគំរូដែលបានអនុម័តរួច របស់ក្រសួងពាណិជ្ជកម្ម។

## ២. ការរំលាយក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

### ២.១ មូលហេតុនៃការរំលាយក្រុមហ៊ុន

ក្រុមហ៊ុនអាចត្រូវបានរំលាយដោយសារមូលហេតុច្រើនយ៉ាង ដូចជា មូលហេតុផ្ទុយច្បាប់ (កិច្ចសន្យាក្រុមហ៊ុនត្រូវចាត់ទុកជាមោឃៈ) ហេតុដែលមានចែងក្នុងកិច្ចសន្យាកើតឡើង (ជាអាទិ៍ ការមកដល់នៃពេលវេលា)

កម្មវត្ថុនៃអាជីវកម្មបានបញ្ចប់ ការព្រមព្រៀងរបស់សមាជិក អលទ្ធភាពបន្តអាជីវកម្ម ខុសលក្ខខណ្ឌកំណត់ដែលតម្រូវឱ្យមានអត្ថិភាព (ឧទាហរណ៍ មានសមាជិកតែម្នាក់) សេចក្តីសម្រេចរបស់តុលាការឱ្យរំលាយ ***ការរំលាយបញ្ចូលគ្នាហើយមិនមានអត្ថិភាពក្រុមហ៊ុនដើម***[18] សេចក្តីសម្រេចរបស់មហាសន្និបាត ។ល។

**ការរំលាយតាមកម្មវត្ថុះ** ក្រុមហ៊ុនមួយអាចនឹងត្រូវរំលាយ ដោយយោងទៅលើកម្មវត្ថុរបស់ក្រុមហ៊ុននោះត្រូវបានបញ្ចប់ ពោលការបញ្ចប់កិច្ចការដែលជាកម្មវត្ថុរបស់ក្រុមហ៊ុននោះ ដោយស្របទៅតាមការកំណត់នៅក្នុងកម្មវត្ថុ តាំងពីពេលដែលសមាជិកក្រុមហ៊ុនធ្វើការស្នើសុំចុះបញ្ជីក្រុមហ៊ុនរបស់ខ្លួនមកម្ល៉េះ។

**ការរំលាយដោយអលទ្ធភាព ឬក្ស័យធនះ** កត្តាមួយទៀតដែលគេរមែងតែងតែជួបប្រទះនាពេលដែលក្រុមហ៊ុនហៀបនឹងរំលាយ គឺបណ្តាលមកពីកង្វះលទ្ធភាពផ្នែកហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ឬគ្មានលទ្ធភាពក្នុងការធ្វើអាជីវកម្មបន្ត ដែលនាំឱ្យក្រុមហ៊ុននោះ មិនអាចបន្តប្រតិបត្តិការរបស់ខ្លួនជាប្រក្រតី។ ការដែលគ្មានលទ្ធភាពក្នុងផ្នែកហិរញ្ញវត្ថុនេះ ត្រូវបានកំណត់ផងដែរនូវវិធានសម្រាប់អនុវត្តដែលមាននៅក្នុងច្បាប់ស្តីពីក្ស័យធន។

**ការរំលាយដោយការបញ្ចូលគ្នាះ** ក្រុមហ៊ុនពីរ ឬច្រើនរួមបញ្ចូលគ្នាជាក្រុមហ៊ុនតែមួយ ឬអាចបង្រួមចូលគ្នាជាក្រុមហ៊ុនថ្មីមួយផ្សេងទៀត។ ក្រុមហ៊ុនដែលរំលាយហៅថាក្រុមហ៊ុនដើម រីឯក្រុមហ៊ុនដែលទទួលបន្ទុកធ្វើអាជីវកម្មតទៅទៀតហៅថាក្រុមហ៊ុនថ្មី។ ក្រុមហ៊ុនដើមនឹងបាត់បង់នូវនីតិបុគ្គលិកលក្ខណៈ ចាប់ពីថ្ងៃដែលក្រសួងពាណិជ្ជកម្មចេញវិញ្ញាបនបត្របញ្ជាក់ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា។ [...]

ប៉ុន្តែជារួម គេអាចបែងចែករបៀបនៃការរំលាយក្រុមហ៊ុនជា២ប្រភេទ ***គឺការរំលាយក្រុមហ៊ុនដោយស្ម័គ្រចិត្ត និងការរំលាយក្រុមហ៊ុនដោយការបង្ខំ*** ។ ទោះជាការរំលាយក្រុមហ៊ុនធ្វើឡើងដោយមូលហេតុ ឬរបៀបណាមួយក៏ដោយ មុននឹងឈានដល់ការរំលាយក្រុមហ៊ុន គឺគេចាំបាច់ត្រូវធ្វើ***នីតិវិធីជម្រះបញ្ជីជាមុនសិន***។

## ២.២ ការជម្រះបញ្ជី និងការរំលាយក្រុមហ៊ុន

### ក. ការជម្រះបញ្ជី និងការរំលាយក្រុមហ៊ុនដោយស្ម័គ្រចិត្ត[19]

សេចក្តីស្នើសុំត្រូវដាក់ជូនទៅឱ្យម្ចាស់បំណុល និងម្ចាស់ហ៊ុនសម្រាប់សងបំណុលខ្លះ ឬទាំងអស់របស់ក្រុមហ៊ុនក្នុងរយៈពេលដែលបានកំណត់មួយ។ ក្នុងដំណាក់កាលនៃដំណើរការជម្រះបញ្ជី ក្រុមហ៊ុនអាចបន្តអាជីវកម្មរបស់ខ្លួនបាន។ សិទ្ធិរបស់ម្ចាស់បំណុលដែលមានការធានា (ធនាគារជាដើម ដែលមានប្រាក់កម្ចី ឬប័ណ្ណបំណុល) មិនត្រូវបានប៉ះពាល់ធំដុំទេ។ បើគ្មានបំណុលស្មុគស្មាញ នោះការជម្រះបញ្ជីនឹងមានលក្ខណៈងាយស្រួលដោយគ្រាន់តែមានការព្រមព្រៀងរវាងម្ចាស់ហ៊ុន (ចែកទ្រព្យសម្បត្តិគ្នា) និងការធ្វើសវនកម្មលើការបង់ពន្ធឱ្យបានត្រឹមត្រូវរួចរាល់ នោះគេអាចដាក់ពាក្យស្នើសុំរំលាយក្រុមហ៊ុនទៅក្រសួងពាណិជ្ជកម្មបាន។ មានន័យថាះ

- បើក្រុមហ៊ុនគ្មានប័ណ្ណភាគហ៊ុន ការរំលាយអាចធ្វើឡើងតាមសេចក្តីសម្រេចរបស់អភិបាលទាំងអស់
- បើក្រុមហ៊ុនមានប័ណ្ណភាគហ៊ុន ការរំលាយអាចធ្វើឡើងតាមសេចក្តីសម្រេចពិសេស របស់ម្ចាស់ហ៊ុន (ករណីមានភាគហ៊ុនច្រើនប្រភេទ ការរំលាយត្រូវសម្រេចដោយអ្នកកាន់កាប់ភាគហ៊ុននៃប្រភេទនីមួយៗ) ទោះម្ចាស់ហ៊ុននោះមានសិទ្ធិ ឬគ្មានសិទ្ធិបោះឆ្នោតក៏ដោយ។

ការរំលាយដោយស្ម័គ្រចិត្តនេះ ក្រុមហ៊ុនត្រូវទៅកាន់នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម និងបំពេញបែបបទចាំបាច់មួយចំនួនដើម្បីសុំលុបឈ្មោះក្រុមហ៊ុនចេញពីបញ្ជីពាណិជ្ជកម្ម។

**ជំហានទី១ះ** ការស្នើសុំរំលាយក្រុមហ៊ុន ត្រូវជូននាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនូវឯកសារមួយចំនួនដូចជា ពាក្យស្នើសុំគំរូ ត ប័ណ្ណជម្រះបញ្ជីសារពើពន្ធចេញដោយនាយកដ្ឋានពន្ធដារ ប្រតិវេទន៍ប្រចាំឆ្នាំស្តីពីសហគ្រាសពាណិជ្ជកម្ម រូបថតទំហំ (៤x៦cm) និងអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនថតចម្លង របស់ម្ចាស់ហ៊ុន

---

[18] ចំពោះនីតិវិធីនៃការរំលាយក្រុមហ៊ុនបញ្ចូលគ្នា មានកំណត់នៅក្នុងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ពីមាត្រា២៤២ ដល់២៥០។

[19] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ពីមាត្រា២៥១ ដល់មាត្រា ២៦៦។

ឬអភិបាលដែលមានចុះហត្ថលេខាឬស្នាមមេដៃ ដែលមកបង្ហាញខ្លួននៅក្រសួងពាណិជ្ជកម្ម ដើម្បីចុះហត្ថលេខាលើពាក្យស្នើសុំ លក្ខន្តិកៈក្រុមហ៊ុនដែលចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្ម អាជ្ញាប័ណ្ណ និងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មដែលចេញដោយក្រសួងពាណិជ្ជកម្ម លិខិតស្នើសុំពីក្រុមហ៊ុន កំណត់ហេតុរំលាយក្រុមហ៊ុន និងសេចក្តីសម្រេចរបស់ក្រុមហ៊ុនមេ ប្រសិនបើពាក់ព័ន្ធ។ កម្រៃរដ្ឋបាលផ្លូវការ គឺ២០០.០០០រៀល។

**ជំហានទី២៖** នៅពេលដែលឯកសារទាំងឡាយដូចបានរៀបរាប់ខាងលើ ត្រូវបានបំពេញគ្រប់គ្រាន់ អភិបាល ឬម្ចាស់ហ៊ុន ត្រូវទៅក្រសួងពាណិជ្ជកម្មដើម្បីចុះហត្ថលេខាលើឯកសារផ្លូវការ។ (ករណីពាក្យស្នើសុំធ្វើឡើងនៅសាខាចុះបញ្ជីពាណិជ្ជកម្មខេត្ត នោះការបង្ហាញខ្លួនដើម្បីចុះហត្ថលេខាក៏ត្រូវធ្វើឡើងនៅទីនោះដែរ)។

**ជំហានទី៣៖** ដំណើរការនេះចំណាយពេល៥ថ្ងៃនៃថ្ងៃធ្វើការ ដើម្បីចេញលិខិតលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម។

**ខ. ការជម្រះបញ្ជី និងការរំលាយក្រុមហ៊ុនដោយការបង្ខំ (ឬដោយការបង្គាប់របស់តុលាការ)**

ការរំលាយក្រុមហ៊ុនដោយការបង្ខំ ទាមទារឱ្យមានមនុស្សម្នាក់ទទួលបន្ទុកធ្វើការជម្រះបញ្ជី ដែលគេហៅថា អ្នកជម្រះបញ្ជី (Liquidator) ឬអ្នករដ្ឋបាលបណ្តោះអាសន្ន (Administrator បណ្តោះអាសន្ន)។ ម្ចាស់ហ៊ុន ឬអភិបាលត្រូវសុំទៅតុលាការដើម្បីសុំបើកនីតិវិធីក្ស័យធន។ តុលាការត្រូវចេញដីកាបើកនីតិវិធីក្ស័យធន ដោយត្រូវចាត់អ្នកជម្រះបញ្ជី ឬអ្នករដ្ឋបាលបណ្តោះអាសន្នម្នាក់មកសិក្សា វាយតម្លៃ និងចាត់ចែងបញ្ហាទ្រព្យ បំណុល និងមូលធន។ អ្នកជម្រះបញ្ជី ឬអ្នករដ្ឋបាលបណ្តោះអាសន្ន ត្រូវរកវិធីយ៉ាងណាដើម្បីបំលែងទ្រព្យ បំណុល និងមូលធនរបស់ក្រុមហ៊ុនដែលមានឱ្យទៅជាសាច់ប្រាក់សុទ្ធ ដើម្បីអាចយកទៅសងបំណុលបាន។ អ្នកជម្រះបញ្ជី ឬអ្នករដ្ឋបាលបណ្តោះអាសន្ន ត្រូវជូនដំណឹងដល់ម្ចាស់បំណុលទាំងអស់។ ចំពោះបញ្ហាបំណុល អ្នកជម្រះបញ្ជី ឬអ្នករដ្ឋបាលបណ្តោះអាសន្ន ត្រូវពិនិត្យមើលថាតើម្ចាស់បំណុលណាខ្លះដែលមានអាទិភាព និងណាខ្លះមិនមានអាទិភាព ក្នុងការទទួលបានសំណង។ បើទ្រព្យនៅសល់តិចជាងបំណុលដែលមាន នាំឱ្យម្ចាស់បំណុល ឬឥណទាយកខ្លះទទួលបានការសងតិចតួច ឬមិនបានទទួលសំណងទាល់តែសោះ។ តែបើទ្រព្យសល់ច្រើនជាងបំណុល នាំឱ្យតុលាការ តាមរយៈអ្នករដ្ឋបាល មិនតម្រូវឱ្យរំលាយតាមរបៀបក្ស័យធនឡើយ តែត្រូវជំនួសមកវិញដោយការបង្កើត (Reconstruction) ក្រុមហ៊ុនឡើងវិញ។ ករណីខ្លះ គេប្រកាសបើកនីតិវិធីក្ស័យធន ប៉ុន្តែបែរជាមិនក្ស័យធនទៅវិញ ហើយក្រុមហ៊ុនបែរជាអាចបន្តរស់ឡើងវិញដោយសារបំណុលរបស់ក្រុមហ៊ុន ត្រូវបានរៀបចំឡើងវិញ ដែលជាហេតុបណ្តាលឱ្យស្ថានភាពបំណុលទាបជាងទ្រព្យវិញ។ ឧទាហរណ៍ ម្ចាស់បំណុលអនុញ្ញាតឱ្យពន្យាពេលសង ហើយខ្លះកាត់បន្ថយបំណុលដោយប្រែខ្លួនជាម្ចាស់ភាគហ៊ុន (Ownership)។

ផលដែលសល់ពីការជម្រះបញ្ជី ត្រូវបង់ទៅលើ៖

- ប្រាក់ខែរបស់បុគ្គលិក ប្រាក់ប្រដាប់ក្តី
- ម្ចាស់បំណុលដែលមានអាទិភាព (មានឯកសិទ្ធិ)
- ម្ចាស់បំណុលដែលគ្មានឯកសិទ្ធិ
- បំណុលពន្ធរបស់រដ្ឋ និងបំណុលផ្សេងទៀត។

អ្នកជម្រះបញ្ជីរបស់ក្រុមហ៊ុន ត្រូវបញ្ចប់នីតិវិធីជម្រះបញ្ជី ដោយធ្វើការតម្កល់ទុកនូវ សេចក្តីជូនដំណឹងអំពីការបិទបញ្ជីនោះ នៅក្រសួងពាណិជ្ជកម្មតាមបែបបទដែលបានកំណត់ទុកដោយច្បាប់។ ការតម្កល់ទុកឯកសារនេះ គឺជាការលុបចោលនូវនីតិបុគ្គលិកលក្ខណៈរបស់ក្រុមហ៊ុននោះឯង មានន័យថា ការប្រកាសរំលាយក្រុមហ៊ុន គឺជាការរំលាយនីតិបុគ្គល។ ម៉្យាងវិញទៀត វាក៏ជានីតិវិធីមួយដែលធ្វើការបើកផ្សាយយ៉ាងទូលាយផងដែរ ទៅឱ្យម្ចាស់បំណុលជ្រាប។